# សហព័ន្ធខ្មែរកម្ពុជាក្រោម

KHMERS KAMPUCHEA-KROM FEDERATION

Asia – Australia – Europe – North America

P.O. Box 0193 • Pennsauken • NJ • 08110 • U.S.A. • Tel: (856) 655-3838 • Fax: (856) 583-1503
http://www.khmerkrom.org • Email: info@khmerkrom.org


## សេចក្តីប្រកាសព័ត៌មានបន្ទាន់
## ដកតួនាទី លោក ថាច់ ង៉ុក ថាច់ ពីប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម

*ទីក្រុង Las Vegas រដ្ឋ Nevada សហរដ្ឋអាមេរិក ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៧* - នៅ ខែឧសភា ឆ្នាំ ២០១៦ គណៈកម្មការនាយកបានជ្រើសតាំង លោក ថាច់ ង៉ុក ថាច់ ជាប្រធានប្រតិបត្តិ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។ ចាប់ពីពេលនោះមក លោក ថាច់ ង៉ុក ថាច់ បានប្រព្រឹត្តល្មើសបំពាននូវលក្ខន្តិកៈ និងក្រមប្រតិបត្តិរបស់សហព័ន្ធជាបន្តបន្ទាប់ ។ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ ២០១៦ នៅទីក្រុង Las Vegas ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៧ គណៈកម្មការនាយកបានពិនិត្យឡើងវិញនូវភស្តុតាង នៃការរំលោភបំពានរបស់ លោក ថាច់ ង៉ុក ថាច់ និងពន្យល់យ៉ាងច្បាស់ដល់សមាជិក អំពីអ្វីដែលគាត់បានរំលោភបំពាន ។ ចំនួនសមាជិកនៃគណៈកម្មការនាយកច្រើនជាងពីរភាគបី (២/៣) បានបោះឆ្នោតជាឯកច្ឆ័ន្ទដកហូតសេចក្តីទុកចិត្ត លោក ថាច់ ង៉ុក ថាច់ ពីប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម និងដក លោក ថាច់ ង៉ុក ថាច់ ចេញពីប្រធានគណៈកម្មការប្រតិបត្តិចាប់ពីពេលនេះតទៅ ។ លោក ថាច់ ង៉ុក ថាច់ នឹងមិនមានតួនាទីអ្វីជាផ្លូវការតំណាងសហព័ន្ធខ្មែរកម្ពុជាក្រោម ទៀតឡើយ ៕

លោក ថាច់ វៀន បច្ចុប្បន្ន ជាអធិបតីនៃសហព័ន្ធខ្មែរកម្ពុជាក្រោម នឹងទទួលភារកិច្ចជាប្រធានប្រតិបត្តិជំនួសរហូតដល់ពេលគណៈកម្មការនាយកតែងតាំងប្រធានប្រតិបត្តិថ្មី ។

**ព័ត៌មានបន្ថែមសូមទាក់ទងអ្នកនាំពាក្យសហព័ន្ធខ្មែរកម្ពុជាក្រោម៖**

| | | |
|---|---|---|
| ១. ព្រះតេជព្រះគុណ ត្រឹង ថាច់ យុង | (408) 386-9319 | (សហរដ្ឋអាមេរិក) |
| ២. លោក ថាច់ សាមី | (253) 228-5378 | (សហរដ្ឋអាមេរិក) |
| ៣. លោក ត្រឹង សារុង | (+39) 328-693-6594 | (អ៊ឺរ៉ុប) |